**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

លេខ ៥៧១ ប្រក កសក

# ប្រ កា ស
# ស្តីពី
# វិធានការការពារប្រភេទធនធានជលផលដែលកំពុងរងគ្រោះថ្នាក់

## រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ជលផល
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ១៨៨ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួង ទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល ឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រ និងកែលម្អដីកសិកម្ម ឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូ ទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ៥៣ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០៦ ស្តីពីការធ្វើពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វ និងរុក្ខជាតិព្រៃដែលកំពុងរងគ្រោះថ្នាក់
- បានឃើញអនុក្រឹត្យលេខ ១២៣ អនក្រ.បក ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០០៩ ស្តីពី ការកំណត់ប្រភេទផល ផលិតផលជលផលដែលកំពុងរងគ្រោះថ្នាក់
- យោងតាមសំណើរបស់ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា ប្រធានរដ្ឋបាលជលផល

១

អាស័យដ្ឋានលេខ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
N°.200 Preah Norodom Sangkat Tonle Bassak Khan Chamkarmon B.V.D. Phnom Penh, Cambodia
ទូរស័ព្ទលេខ : (០២៣) ២១១ ៣៥១/២១១ ៣៥២ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone: (023) 211 351/211 352 Fax: (856) 23 217 320

**ជំពូក ១**

**ប្រការ១.-**

ប្រកាសនេះ កំណត់អំពីជានការការពារប្រភេទធនធានជលផលដែលកំពុងរងគ្រោះថ្នាក់ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីការពារ អភិរក្ស និងស្ដារធនធានទាំងនេះឱ្យមាននិរន្តរភាពឡើងវិញ។

**ប្រការ២.-**

ដើម្បីអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាព រដ្ឋបាលជលផលមានតួនាទី និងភារកិច្ច ជាអាទិ៍ :

- សិក្សាស្រាវជ្រាវអំពីប្រភេទ របាយ និងស្ថានភាពនៃធនធានជលផលដែលកំពុងរងគ្រោះថ្នាក់ និងទីជម្រករបស់វា ដើម្បីចាត់វិធានការការពារ អភិរក្ស និងស្ដារឡើងវិញប្រកបដោយប្រសិទ្ធភាព
- កំណត់តំបន់ក្នុងដែនធម្មជាតិ រៀបចំ និងអនុវត្តផែនការការពារ អភិរក្ស និងស្ដារប្រភេទធនធានជលផលដែលកំពុងរងគ្រោះថ្នាក់ឡើងវិញ
- បង្កើតមណ្ឌលសង្គ្រោះមួយចំនួន ក្នុងគោលបំណងប្រើប្រាស់សម្រាប់សង្គ្រោះ ថែរក្សា និងសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រប្រភេទធនធានជលផលដែលកំពុងរងគ្រោះថ្នាក់ទាំងនេះ
- ផ្សព្វផ្សាយឱ្យបានទូលំទូលាយ និងតាមគ្រប់បណ្ដាញនូវប្រភេទធនធានជលផលដែលកំពុងរងគ្រោះថ្នាក់ ដើម្បីជំរុញឱ្យមានការចូលរួមពីប្រជាពលរដ្ឋក្នុងការការពារ និងអភិរក្ស
- សិក្សា ស្រាវជ្រាវ កំណត់ និងវាយតម្លៃនូវប្រភេទធនធានជលផល ដើម្បីជាមូលដ្ឋានក្នុងការកែសម្រួលតារាងប្រភេទធនធានជលផលដែលកំពុងរងគ្រោះថ្នាក់ តាមការចាំបាច់
- ត្រួតពិនិត្យ និងតាមដានការនាំចេញ នាំចូល ដឹកជញ្ជូន និងការចិញ្ចឹមប្រភេទធនធានជលផលក្រៅស្រុក និងប្រភេទរាតត្បាត (Exotic and invasive species)។

**ប្រការ៣.-**

ការចាប់ ការលក់ ការទិញ ការដឹកជញ្ជូន ការប្រមូលផល ការកែច្នៃ និងការធ្វើសន្និធិនូវប្រភេទធនធានជលផលដែលកំពុងរងគ្រោះថ្នាក់ពីដែនទឹកធម្មជាតិ ក្នុងគោលបំណងសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រ ត្រូវមានការអនុញ្ញាតពីប្រធានរដ្ឋបាលជលផល។

**ប្រការ៤.-**

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលបង្កើតកសិដ្ឋានចិញ្ចឹម ឬបង្កាត់ពូជប្រភេទធនធានជលផលដែលកំពុងរងគ្រោះថ្នាក់ សម្រាប់បម្រើការធ្វើពាណិជ្ជកម្មត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម :

១. ការបង្កើតកសិដ្ឋានត្រូវអនុញ្ញាតដោយរដ្ឋបាលជលផលថ្នាក់កណ្ដាល ដោយផ្អែកលើទិន្នន័យវិទ្យាសាស្ត្រ។

២. ត្រូវចុះបញ្ជីកសិដ្ឋាន និងប្រភេទធនធានជលផលដែលកំពុងរងគ្រោះថ្នាក់នៅរដ្ឋបាលជលផល។

២

៣. សកម្មភាពប្រតិបត្តិរបស់កសិដ្ឋាន ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យយ៉ាងតឹងរ៉ឹងរបស់រដ្ឋបាលជលផល និងត្រូវមានសង្គតិភាពជាមួយបទបញ្ញាទាំងឡាយដែលបានកំណត់ក្នុងលិខិតអនុញ្ញាតឱ្យបង្កើតកសិ-ដ្ឋាននោះ។

៤. ការដឹកជញ្ជូន ការកែច្នៃ និងការធ្វើសន្និធិប្រភេទផល ផលិតផលជលផលដែលចេញពីកសិដ្ឋានដែលបានចុះបញ្ជីស្របច្បាប់ ក្នុងគោលបំណងធ្វើពាណិជ្ជកម្មក្នុងស្រុក ត្រូវមានការអនុញ្ញាតពីប្រធានរដ្ឋបាលជលផល។ ចំពោះការធ្វើពាណិជ្ជកម្មក្រៅប្រទេស ត្រូវមានការអនុញ្ញាតពីរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមសំណើរបស់ប្រធានរដ្ឋបាលជលផល។

**ប្រការ៥.-**

ក្នុងករណីធ្វើនេសាទបានដោយចៃដន្យនូវប្រភេទធនធានជលផលដែលកំពុងរងគ្រោះថ្នាក់ អ្នកនេសាទត្រូវមានកាតព្វកិច្ចដោះលែងជាបន្ទាន់ទៅក្នុងដែនទឹកធម្មជាតិវិញ ដោយគ្មានលក្ខខណ្ឌ និងមិនត្រូវធ្វើឱ្យមានរបួសស្នាម ឬសម្លាប់ឡើយ ហើយត្រូវផ្តល់ព័ត៌មានដល់សមត្ថកិច្ចជលផល ឬត្រូវអនុវត្តតាមការណែនាំរបស់មន្ត្រីមានសមត្ថកិច្ចនៃរដ្ឋបាលជលផល។ ក្នុងករណីប្រទះឃើញសាកសព ឬសំណាកនៃធនធានទាំងនេះ ត្រូវផ្តល់ដំណឹង ឬប្រគល់ជូនសមត្ថកិច្ចជលផលជាបន្ទាន់។

**ប្រការ៦.-**

ជនណាដែលត្រូវបានរកឃើញថាបានធ្វើសកម្មភាពផ្សេងៗដែលបង្កគ្រោះថ្នាក់ដល់ប្រភេទធនធានជលផលដែលកំពុងរងគ្រោះថ្នាក់ ត្រូវផ្តន្ទាទោសតាមមាត្រា ៩៨ នៃច្បាប់ស្តីពីជលផល។

**ប្រការ៧.-**

មន្ត្រីរដ្ឋបាលជលផលមានភារកិច្ចត្រួតពិនិត្យ និងចាត់វិធានការ ស្របតាមនីតិវិធី ដើម្បីផ្តន្ទាទោស ឬពិន័យចំពោះជនណាដែលបង្ករបួសស្នាម ឬធ្វើឱ្យស្លាប់ប្រភេទធនធានជលផលដែលកំពុងរងគ្រោះថ្នាក់។

**ប្រការ៨.-**

ជនណាដែលប្រព្រឹត្តល្មើសនឹងប្រកាសនេះ ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ៩.-**

ការចិញ្ចឹមប្រភេទធនធានជលផលដែលកំពុងរងគ្រោះថ្នាក់ ក្នុងគោលបំណងធ្វើពាណិជ្ជកម្ម ត្រូវចុះបញ្ជីនៅរដ្ឋបាលជលផលក្នុងរយៈពេល ១២ (ដប់ពីរ) ខែ គិតចាប់ពីកាលបរិច្ឆេទដែលប្រកាសនេះចូលជាធរមាន។

**ប្រការ១០.-**

ប្រកាស ឬសេចក្តីសម្រេចទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១១.-**

អគ្គលេខាធិការ អគ្គាធិការ ប្រធានសមត្ថកិច្ចគ្រប់គ្រងសាយភាពកម្ពុជា នាយកខុទ្ទកាល័យ ប្រធាន

៣

រដ្ឋបាលជលផល ប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួនឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ... ខែ កញ្ញា ឆ្នាំ ២០១០

**រដ្ឋមន្ត្រី**

**ចាន់ សារុន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងបរិស្ថាន
- ក្រសួងយុត្តិធម៌
- សាលារាជធានី-ខេត្ត
- ដូចប្រការ ១១
- ឯកសារ-កាលប្បវត្តិ

លេខ ២២២៣៧ ជផ

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម និងបញ្ជូនមកថ្នាក់ដឹកនាំ និង

គ្រប់អង្គភាពក្រោមឱវាទរដ្ឋបាលជលផល ព្រមទាំងអង្គការពាក់ព័ន្ធទាំងអស់

"ដើម្បីជ្រាប និងអនុវត្ត"

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០១០

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា**

**ប្រធានរដ្ឋបាលជលផល**

**ណៅ ធួក**